**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ.០០៣.....សហវ.សរ.អកឡ

ថ្ងៃព្រហស្បតិ៍ ២រោច ខែបុស្ស ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែមករា ឆ្នាំ២០២៥

# សារាចរណែនាំ
## ស្តីពី
## ការប្រើប្រាស់វិក្កយបត្រអេឡិចត្រូនិកជាកាតព្វកិច្ច តាមប្រព័ន្ធវិក្កយបត្រអេឡិចត្រូនិកកម្ពុជាដំណាក់កាលទី១ ជំហានទី១

ស្របតាម "យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១" របស់រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា, ក្របខ័ណ្ឌគោលនយោបាយសេដ្ឋកិច្ច និង សង្គមឌីជីថលកម្ពុជា ២០២១-២០៣៥ និងផែនការសកម្មភាពរួមនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី ៤, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានដឹកនាំ និងបញ្ចប់ការអភិវឌ្ឍ **ប្រព័ន្ធវិក្កយបត្រអេឡិចត្រូនិកកម្ពុជា** រួចរាល់ក្នុងការប្រើប្រាស់។ ប្រព័ន្ធវិក្កយបត្រអេឡិចត្រូនិកកម្ពុជា គឺជាប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរបស់រដ្ឋ ដែលមានតួនាទីជាប្រព័ន្ធកណ្តាលសម្រាប់ផ្លាស់ប្តូរវិក្កយបត្រក្នុងទម្រង់ជាអេឡិចត្រូនិករវាងភាគីអ្នកលក់ ឬ អ្នកផ្តល់សេវា និងភាគីអ្នកទិញ ឬ អ្នកទទួលសេវា។ ប្រព័ន្ធនេះមានមុខងារក្នុងការផ្តល់អត្តសញ្ញាណ និងបញ្ជាក់ទទួលស្គាល់វិក្កយបត្រអេឡិចត្រូនិកជាផ្លូវការ ដោយមិនតម្រូវឱ្យមានការបោះពុម្ពវិក្កយបត្រជាក្រដាសទៀតឡើយ។ ប្រព័ន្ធវិក្កយបត្រអេឡិចត្រូនិកកម្ពុជា គឺជាឧបករណ៍សម្រាប់ជំរុញការប្រើប្រាស់វិក្កយបត្រអេឡិចត្រូនិកក្នុងព្រះរាជាណាចក្រកម្ពុជា ដែលសំដៅលើកកម្ពស់តម្លាភាព និងគណនេយ្យភាពនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដើម្បីគាំទ្រដល់ការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី ៤ របស់រាជរដ្ឋាភិបាលកម្ពុជា, ចូលរួមពង្រឹងអនុលោមភាពបទប្បញ្ញត្តិសារពើពន្ធ, ចូលរួមសម្រេចគោលដៅនៃការអភិវឌ្ឍប្រកបដោយចីរភាព និងត្រៀមខ្លួនចូលរួមកិច្ចសហប្រតិបត្តិការ និងសមាហរណកម្មសេដ្ឋកិច្ចឌីជីថលអាស៊ាន។ ដើម្បីជំរុញការប្រើប្រាស់វិក្កយបត្រអេឡិចត្រូនិក, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដាក់ចេញនូវសារាចរណែនាំ ស្តីពីការប្រើប្រាស់វិក្កយបត្រអេឡិចត្រូនិកជាកាតព្វកិច្ច តាមប្រព័ន្ធវិក្កយបត្រអេឡិចត្រូនិកកម្ពុជាជាជំហានៗ ដែលចាប់ផ្តើមអនុវត្តចំពោះប្រតិបត្តិការវិក្កយបត្ររវាងក្រុមហ៊ុន ឬ អ្នកផ្គត់ផ្គង់ជាមួយក្រសួង-ស្ថាប័ន ឬ អង្គភាពរដ្ឋ។

សារាចរណែនាំសម្រាប់ការអនុវត្តដំណាក់កាលទី១ ជំហានទី១ នេះ មានវិសាលភាពចំពោះអង្គភាពថវិកាថ្នាក់កណ្តាល នៃក្រសួងចំនួន ២ គឺ **១-ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** និង **២-ក្រសួងបរិស្ថាន** ព្រមទាំងក្រុមហ៊ុន ឬ អ្នកផ្គត់ផ្គង់នៃក្រសួងទាំងពីរ និងគ្របដណ្តប់លើវិក្កយបត្រសម្រាប់ការស្នើសុំទូទាត់ចំណាយ ដែលឆ្លងកាត់ការអនុវត្តកិច្ចលទ្ធកម្មដោយគិតចាប់ពីឆ្នាំសារពើពន្ធ ២០២៥ តទៅ។

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សូមធ្វើការណែនាំដល់អង្គភាពថវិកាថ្នាក់កណ្តាល នៃក្រសួងទាំងពីរខាងលើ, ក្រុមហ៊ុន ឬ អ្នកផ្គត់ផ្គង់នៃក្រសួងទាំងពីរ និងស្ថាប័ន ឬ អង្គភាពដែលមានការពាក់ព័ន្ធដូចតទៅ៖

### ក. អង្គភាពថវិកាថ្នាក់កណ្តាលនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង ក្រសួងបរិស្ថាន

១.ត្រូវទទួលយកតែវិក្កយបត្រអេឡិចត្រូនិកប៉ុណ្ណោះ សម្រាប់ការទូទាត់ចំណាយតាមនីតិវិធីលទ្ធកម្ម។ **វិក្កយបត្រអេឡិចត្រូនិក** សំដៅដល់វិក្កយបត្រដែលបានបញ្ជូនក្នុងទម្រង់ជាអេឡិចត្រូនិកឆ្លងកាត់ការពិនិត្យ និង



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
mef.gov.kh
t.me/mefcambodia
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666
info@mef.gov.kh
mef.cabinet@mef.gov.kh

ផ្តល់អត្តសញ្ញាណជាវិក្កយបត្រអេឡិចត្រូនិកដោយប្រព័ន្ធវិក្កយបត្រអេឡិចត្រូនិកកម្ពុជា។

២.ត្រូវផ្តល់ដំណឹងទៅក្រុមហ៊ុន ឬ អ្នកផ្គត់ផ្គង់របស់ខ្លួន ឱ្យចុះឈ្មោះចូលជាសមាជិកនៃប្រព័ន្ធវិក្កយបត្រអេឡិចត្រូនិកកម្ពុជា ដើម្បីប្រើប្រាស់វិក្កយបត្រជាទម្រង់អេឡិចត្រូនិក ក្នុងករណីមិនទាន់ក្លាយជាសមាជិក។

៣.អង្គភាពថវិកាថ្នាក់កណ្តាលនៃក្រសួងទាំងពីរនឹងក្លាយជាសមាជិកនៃប្រព័ន្ធវិក្កយបត្រអេឡិចត្រូនិកកម្ពុជាដោយស្វ័យប្រវត្តិ។ អង្គភាពនីមួយៗត្រូវចាត់តាំងតំណាងក្នុងការគ្រប់គ្រងព័ត៌មានសមាជិកភាពរបស់ខ្លួននៅក្នុងប្រព័ន្ធវិក្កយបត្រអេឡិចត្រូនិកកម្ពុជាតាមរយៈផតថលវិក្កយបត្រអេឡិចត្រូនិកកម្ពុជា ព្រមទាំងអាចទទួលវិក្កយបត្រអេឡិចត្រូនិកពីក្រុមហ៊ុន ឬ អ្នកផ្គត់ផ្គង់តាមរយៈផតថលនេះ។ ក្នុងកំឡុងពេលដែលប្រព័ន្ធវិក្កយបត្រអេឡិចត្រូនិកកម្ពុជាមិនទាន់បានភ្ជាប់ និងដាក់ដំណើរការសន្ទានកម្មជាមួយប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ អង្គភាពថវិកាថ្នាក់កណ្តាលអាចប្រើប្រាស់វិក្កយបត្រអេឡិចត្រូនិកនោះទៅ អនុវត្តនីតិវិធីទូទាត់បន្តដូចការអនុវត្តបច្ចុប្បន្ន។ ការចាត់តាំងតំណាង គឺត្រូវបញ្ជូនលិខិតផ្លូវការទៅប្រតិបត្តិករនៃប្រព័ន្ធវិក្កយបត្រអេឡិចត្រូនិកកម្ពុជា។

## ខ.ក្រុមហ៊ុន ឬ អ្នកផ្គត់ផ្គង់

១.ការចេញវិក្កយបត្រទៅអង្គភាពថវិកានៃក្រសួងទាំងពីរខាងលើ ត្រូវតែជាវិក្កយបត្រអេឡិចត្រូនិក។

២.ត្រូវចុះឈ្មោះជាសមាជិកនៃប្រព័ន្ធវិក្កយបត្រអេឡិចត្រូនិកកម្ពុជា ដើម្បីអាចប្រើប្រាស់ប្រព័ន្ធវិក្កយបត្រអេឡិចត្រូនិកកម្ពុជាបាន។ ការចុះឈ្មោះជាសមាជិក ត្រូវអនុវត្តតាមវិធាន និងនីតិវិធីនៃការចូលជាសមាជិកនៃប្រព័ន្ធវិក្កយបត្រអេឡិចត្រូនិកកម្ពុជា។

៣.វិក្កយបត្រអេឡិចត្រូនិកអាចបង្កើតចេញតាមរយៈផតថលវិក្កយបត្រអេឡិចត្រូនិកកម្ពុជា ឬ ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការចេញវិក្កយបត្រណាមួយ ដែលបានចុះបញ្ជីទទួលស្គាល់ និងបានភ្ជាប់ដំណើរការសន្ទានកម្មរួចរាល់ជាមួយនឹងប្រព័ន្ធវិក្កយបត្រអេឡិចត្រូនិកកម្ពុជា។

## គ.អគ្គនាយកដ្ឋាននៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

១.អគ្គនាយកដ្ឋានសេដ្ឋកិច្ចឌីជីថល ត្រូវដើរតួនាទីជាប្រតិបត្តិករនៃប្រព័ន្ធវិក្កយបត្រអេឡិចត្រូនិកកម្ពុជា។

២.អគ្គនាយកដ្ឋានថវិកា និងអគ្គនាយកដ្ឋានរតនាគារជាតិ ត្រូវចូលរួមពិនិត្យ និងពង្រឹងលើការប្រើប្រាស់វិក្កយបត្រអេឡិចត្រូនិក នៅក្នុងវំហូរនីតិវិធីសម្រាប់ការស្នើទូទាត់ចំណាយរបស់អង្គភាពថវិកានៃក្រសួងទាំងពីរដែលតម្រូវឱ្យអង្គភាពស្នើទូទាត់តាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ភ្ជាប់មកជាមួយបន្ថែមនូវវិក្កយបត្រអេឡិចត្រូនិក។ ករណីពិនិត្យឃើញថាវិក្កយបត្រដែលភ្ជាប់មកមិនអាចផ្ទៀងផ្ទាត់ជាមួយប្រព័ន្ធវិក្កយបត្រអេឡិចត្រូនិកកម្ពុជា អាចធ្វើការបដិសេធ។

ទទួលបានសារាចរនេះ គ្រប់អង្គភាពពាក់ព័ន្ធ ដែលស្ថិតក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងបរិស្ថាន ក្រុមហ៊ុន ឬ អ្នកផ្គត់ផ្គង់ ព្រមទាំងភាគីដែលមានការពាក់ព័ន្ធ ត្រូវអនុវត្តឱ្យមានប្រសិទ្ធភាព និងដោយស្មារតីទទួលខុសត្រូវខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ